# រឿង មហាចោរនៅទល់ដែន

## ភាគទី២១

នាងទេវី ដែលដួលសន្លប់ ស្តូកស្តឹងលើគ្រែនោះ ក៏បានបើកភ្នែកឡើងៗ នាងមើលឃើញ មុខនាងកួង ដែលមានទឹកភ្នែក ហូររហាមៗ ជីតាឱបនាងកួងយំ ហើយពោលយ៉ាងរវើរវាយថា៖

- បង ! បង ! បង ! . . . នេះប្អូន !

នាងកួងឃើញដូច្នោះ ខំបមបីស្រីថែមទៀតៗ

- កូន ! កូន ! នេះម៉ែ ! ម៉ែណា !
- ចាំ៎ះ ! ម៉ែ!
- អី ! នេះម៉ែ!
- ចាំ៎ះ បង ! បងទៅណាហើយ បងគាត់ខឹងខ្ញុំទេ? ទេប្អូនឥតក្បត់បងទេ ! ប្អូនស្រលាញ់បងនឹកបងណាស់ៗ

នាងភ័យរឹតតែខ្លាំងឡើង ៗ ស្ត្រីជាម្តាយញ័រ អស់សព្វសព៌ាង្គកាយ នាងទេវីបិទភ្នែកជិតស្លុង មាត់ចេះតែនិយាយៗទៅ គ្មានដឹងខ្លួនប្រាណសោះៗ

- ម៉ែ ! ម៉ែ ! បងគាត់ទៅណាហើយ ? អូ ! ប្រហែលគាត់ខឹងនឹងខ្ញុំមែនហើយ ។ អូ ! គាត់មិនដឹងរឿងទេ . . . ៗ
- កូន !ទេវី ! កូនមាសម្តាយ ! កូននិយាយអី ដូច្នោះ ? កូន ! កូន !

នាងកួងអង្រួន នាងទេវីយំរឹតតែខ្លាំងឡើងៗ

- ទេ ! កុំៗ សម្លាប់កូនខ្ញុំអី ! ទុកជីវិតកូនខ្ញុំ ឲ្យរស់នៅសិន ! ហ៊ឺបង! កុំជឿពាក្យគេៗ ទេ . . . កូន . . . លោកឱស ៗ ស្លាប់ខ្ញុំហើយ ! ទេខ្ញុំចង់រស់ . . . !

អត្ថបទដោយ៖ មាស សុភាព

នាងកួងគ្រវីក្បាល ហួសចិត្ត មិនដឹងគិតយ៉ាងណា ដើម្បីឲ្យកូនសម្លាញ់របស់គាត់និយាយត្រឹមត្រូវវិញ។

- កូនៗ កុំនិយាយ ! កូនទៅឲ្យស្ងៀម !
- ចាំ ! ខ្ញុំមិនហ៊ាននិយាយទេ ខ្ញុំខ្លាចកូនខ្ញុំស្លាប់។ តែមិនឲ្យខ្ញុំនិយាយឯណាបាន បងគាត់ខឹងនឹងខ្ញុំងាប់ហើយ។ ...បង បង..! បង កុំជឿតាមគេណា ! អាណិតប្អូនទៅ កុំជឿតាមគេ។

ញើសហូរចេញពីថ្ងាសនាងទេវី ផ្ោតៗ ។ នាងកួងយកកូនកន្សែងជូតញើសនោះបណ្តើរនិយាយបណ្តើរ៖

- ឱ! ព្រះម្ចាស់ថ្លៃអើយ ! សូមជួយកូនខ្ញុំផង កុំឲ្យកូនខ្ញុំនិយាយច្រើនពេក ។ កូន ៗ ! កូនសម្ងំឲ្យលក់ទៅ ។
- ចាំះ !
- អឺ ! កូននៅឲ្យស្ងៀមកុំនិយាយអី ។
- ចាំះ !
- បើកូនស្លាប់ ម៉ែក៏ស្លាប់ដែរ ។
- ចាំះ !
- កូនមិនស្លាប់ទេ ព្រោះមានម៉ែ ។
- ចាំះ !

មួយស្របក់ក្រោយមក នាងទេវីក៏ដេកលក់ ស្កប់ស្កល់។ ដល់នាងភ្ញាក់ឡើង ធីតាហាក់មានកម្លាំងកំហែង។ កល្យាណក្រោកដើរទៅមុជទឹក រួចទើបនិយាយ ទៅកាន់នាងកួងទៀតថា៖

- ម្តាយអើយ ! ក្នុងជាតិនេះ កូនអភ័ព្វណាស់ ។ បងមានទ្ធមកទីនេះ អំបាញ់មិញ។ កូនមិនហ៊ានមើលមុខបងទេ ពីព្រោះអាកាមា វាសម្លាប់កូនរបស់ខ្ញុំ។ ម្តាយមាសម្តាយ ! បើម្តាយឃើញបទុមកូនខ្ញុំ ម្តាយមុខជាស្លាប់មិនខាន។ អាកាមា វាឲ្យមនុស្សអសិរពិសម្នាក់ យក

ដាវដាក់ចំកកូនខ្ញុំ ដើម្បីបង្ខំកុំឲ្យខ្ញុំនិយាយអ្វី ធ្វើអ្វី។ ក្នុងពេលនោះ អាកាមា វាបង្គាប់ថាខ្ញុំនឹងវា សហាយគ្នា។ ឱ អ្នកម្ដាយ! កូនស្លាប់តែក្នុងថ្ងៃនេះឯង ជាប្រាកដហើយ។ កូនឈឺចិត្តណាស់ អាកាមាវាធ្វើបាបកូនដល់ហើយ . . . ។ ឱ! ឥឡូវកូនខ្ញុំទៅណា បាត់ពីបង្អួចនោះហើយ...? អំបាញ់មិញ ខ្ញុំមើលឃើញកូនខ្ញុំ ពីទីនេះទៅ។ វាយកកូនខ្ញុំ ទៅទៀតហើយ។ កូនខ្ញុំដេកលក់ គ្មានដឹងថាជីវិត នៅនឹងចុងដាវគេទេ មានតែខ្ញុំទេ ដឹងភ័យ ស្រៀវ ទុក្ខ។ នាងដេកលក់ ព្រងើយ។ ឯខ្ញុំ ស្ទើរស្លាប់ខ្លួន។ ឱ! ម្ដាយអើយ! កូននឹករលឹកបងមានន្ទខ្លាំងណាស់។ កូនប្រុងកាយប្រុងចិត្តថា កូនផុតទុក្ខ ថ្ងៃនេះហើយ។ តែឥឡូវ កូនរឹតតែមានទុក្ខទៅទៀត កូនឃើញគេមក កូនស្ទើរស្ទុះទៅឱបជើងគេ ។ កូនឃើញតែជើងគេទេ។ កូនឥតបានឃើញមុខគេទេ។ គេខឹងនឹងកូនហើយ។ គេនិយាយមករកកូនដែរ តែកូនពុំហ៊ានឆ្លើយ។ គេគំហកកូន តែកូននឹកថា បើគ្មានអាកាមាទេ គេគំហកយ៉ាងណា ក៏កូនមិនថាដែរ កូនមុខជាឲ្យគេគំហកតាមចិត្ត ឲ្យតែកូនបានព្ទសម្លេងគេ បានស្ដាប់សម្ដីគេ ទោះសម្ដីនោះ ទ្រគោះបោះបោកយ៉ាងណាក៏ដោយ។ ម្ដាយអើយ! ហេតុតែកូនស្រលាញ់គេ។ ឥឡូវគេមិនដឹងរឿង គេទៅបាត់ ទុកតែស្នាមជើងនៅទីនេះ។ កូនសូមថើបធូលីជើងគេហើយ អ្នកម្ដាយកុំថាឲ្យកូន កុំសើចកូន។ ចាំះ! កូនថើប ដោយឥតអៀនខ្មាសទេ។ ឥឡូវកូនក៏បាត់ ប្ដីបាត់ តើឲ្យកូនទៅណា? ធ្វើអ្វី ?គិតអ្វី? កូនអស់រលីងហើយ។ អ្នកម្ដាយ។ ជួយគិតគូរកូនផង។ ឱ!...!

ក្នុងពេលនោះ មនុស្សម្នាក់ មាឌមាំ អាយុប្រមាណហាសិបប្លាយឆ្នាំ ចូលមកបីកូនមកផង។ នាងទេវីស្គាល់ជាក់ ជាកូនខ្លួន ក៏ស្ទុះរត់មកលុតជង្គង់ ពីមុខបុរសពុំស្គាល់នោះ លាតដៃទាំងពីរ...។ បុរសអង្គុយចុះ ទឹកមុខញញឹម ហុចកូនទៅឲ្យនាង។

- លោក ៗ កូនខ្ញុំមែនទេ?
- បាទ! កូននាងហើយ!
- ឱ! ព្រះម្ចាស់ថ្លៃអើយ! កូនខ្ញុំមែន!
- ខ្ញុំលួចគេយកមកជូននាងវិញ។
- ចាំះ ខ្ញុំសូមអរគុណលោកណាស់ វាលាក់កូនខ្ញុំឯណាលោក?

អត្ថបទដោយៈ មាស សុភាព

- មិនសំខាន់ទេ សំខាន់ត្រង់ខ្ញុំយកកូនមកជូននាងវិញ។
- ចាំះ ! លោកខ្ញុំអរគុណលោកណាស់ រកអ្វីមកប្រៀបគ្មានទេ។ ឱ ! លោកហៅ ចំជាមានគុណានឹងខ្ញុំមែន តែខ្ញុំក្រណាស់ លោក

ចង់បានអ្វីពីខ្ញុំ ឲ្យតែខ្ញុំមាន ខ្ញុំជូនលោកទាំងអស់។

- ទេ ! ខ្ញុំធ្វើនេះឥតមានចង់បានអ្វីពីនាងទេ។
- ចាំះ ! ចាំះ ! លោកមានចិត្តអ្វីល្អម្ល៉េះទេ។ លោកឈ្មោះអី ? នៅឯណា ? ដើម្បីឲ្យខ្ញុំបានដឹង ឲ្យខ្ញុំបានទឹកគុណអស់មួយ

ជីវិតខ្ញុំ។

- ខ្ញុំជាមនុស្សឥតឈ្មោះ ឥតទីលំនៅ ឥតគ្រួសារទេ . . . ។
- ហ៊ឺ ! លោកកុំខ្លាចខ្ញុំ កុំលាក់ខ្ញុំ ប្រាប់ខ្ញុំមក!
- ទេ ! ខ្ញុំឥតខ្លាចអ្វីទេ គឺជាការពិតដូច្នោះឯង។
- ចាំះ ! លោកជាមនុស្សអីប្លែកម្ល៉េះទេ។
- បើដូច្នោះ កិច្ចខ្ញុំសម្រេចហើយ ខ្ញុំសូមលាអ្នកហើយ។
- ចាំះ ទេ ! សូមចាំអញ្ជើញពិសាបាយ នឹងខ្ញុំសិន។
- បាទទេ ! ខ្ញុំសូមអរគុណណាស់ហើយ។ ខ្ញុំមានការប្រញាប់បន្តិច ។
- ហ៊ឺ ! លោកមានការអ្វី ?
- ការផ្តាល់ខ្លួន។ ខ្ញុំសូមលាអ្នក សូមអ្នកនៅឲ្យសុខសប្បាយណ៎ា !
- ចាំះ ! លោកអញ្ជើញទៅណាមកណា សូមអាណិតចូលលេងផ្ទះខ្ញុំផងកុំខាន។
- បាទ ! អរគុណនាងណាស់!
- ចុះលោកស្គាល់ប្តីខ្ញុំទេ?
- បាទស្គាល់ តែឥឡូវអ្នកស្រុកប្រាប់ថា ឈ្មោះគ្នាយ៉ាងខ្លាំងជាមួយមេទ័ពកាមា ចាក់គ្នាឯវាលស្រែឯណោះ តាំងពីល្ងាចម្ល៉េះ រួចកាមាក៏ចាញ់ទៅ។ ឥឡូវ ព្ទជាជិះសេះទៅខាងត្បូងបាត់ទៅហើយ។ មិនដឹងជាទៅណាផង។

អត្ថបទដោយ៖ មាស សុភាព

- តាមស្មានប្រហែលទៅណា ?
- ប្រហែលទៅបាត់ដំបង!
- ឱ ! ចា៎ះ សូមអរគុណលោកហើយ អញ្ជើញចុះឲ្យសុខសប្បាយ ឲ្យមានជ័យជំនះឈ្នះអស់មារ សត្រូវៗ ទាំងប្រាំបីទិស។

មនុស្សមិនស្គាល់មុខនេះ ក៏លោតលើខ្នងសេះទៅបាត់ទៅ។ នាងទេវី ក៏ក្រសោបបុត្រីថើបៗ នាងនិយាយថា៖

- កូនៗ ! ម្ដាយនឹកកូនណាស់ ម្ដាយស្មានតែពុំបានជួបមុខកូន ពុំបានឃើញកូនទៀតទេ ។ កូនកុំដេកអី ក្រាក់ឡើង។

នាង បទុមក៏ក្រាក់ ដោយនាងទេវីញក់ញីខ្លាំងពេក។ នាងសើចគ្រហាញដាក់ម្ដាយ ដែលធ្វើឲ្យនាងទេវី រឹតតែសប្បាយចិត្តទៅ ទៀតនាងយំបណ្ដើរផង។

- កូន ! កូនអត់ត្រូវគេធ្វើបាបអ្វី ទេឬ? កូននៅសុខសប្បាយទេ ? ម្ដាយមិនស្មានដូច្នោះសោះ នឹកខុសថាប្រហែលគេញក់ញី អារ

សាច់ ហុតឈាមទៅហើយ។ ម្ដាយយំខ្លាំងណាស់ប៉ុន្មានថ្ងៃនេះៗ ទៅកូន ! ទៅជាមួយម្ដាយ ទៅរកឪពុកកូនឯងទៀត។

ថាដូច្នោះហើយ នាងទេវីរកកន្សែងដណ្ដប់ឲ្យនាងបទុម រួចប្រាប់នាងក្លងថា៖

**(សូមរង់ចាំតាមដានភាគទី២២ នៅសប្ដាហ៍ក្រោយ)**

អត្ថបទដោយ៖ មាស សុភាព